ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 04-May-2012, 09:00
CMS/CFO: Kauv Keoratanak

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្ដីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី៦០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ត់

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី
*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គីមសួន

លោក សំ សុគង់

លោកស្រី ស៊ីន សុវ៉ន

លោក ឡៅ ជុនធី

លោក វ៉ែន ពៅ

លោក បាណាបេ ណេគ្វី
*(Mr. Barnabé NEKUIE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីនូហ្វ៊ី | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ពាន ឃាន (TCW-504) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោក ពាន ឃាន** (TCW-504)
បន្តសួរដោយលោក អាប់ឌុលឡាក់ ថារីក ផ្តើមពី៖........................................................ទំព័រ ៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៣២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមកាលបរិច្ឆេទដែលបានគ្រោងទុក នៅថ្ងៃនេះយើងបន្តស្តាប់សក្ខីកម្មសាក្សី ពាន ឃាន ដែលនឹងបន្តការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា។ ប៉ុន្តែដោយព្រឹកនេះយើងមានបានទទួលនូវសំណើសុំមួយចំនួន។ អ៊ីចឹងហើយយើងនឹងដោះស្រាយបញ្ហាសំណើជាមុនសិន។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:០៣:៣៤]

**លោក អាប់ឌុលឡាក់ ថារីក៖**

អរុណសួស្តីលោក លោកស្រីចៅក្រម។ សូមអរគុណលោកប្រធាន។ យើងខ្ញុំបានធ្វើ ទាក់ទងជាមួយនឹងមន្ត្រីច្បាប់ដោយស្នើសុំពេលវេលាបន្ថែមមួយចំនួន មុនពេលដែលកោះហៅសាក្សីចូលមក។ លោក លោកស្រីចៅក្រម ខ្ញុំថ្លែងអំណរគុណដែលអនុញ្ញាតឲ្យខ្ញុំលើកចំណុចនេះឡើង។

ជាសង្ខេបយើងបានស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះមួយចំនួន។ យើងខ្ញុំស្នើពេលវេលាបន្ថែមដើម្បីដេញដោលសាក្សីនេះ។ វាបង្ហាញយ៉ាងច្បាស់ជូនយើងទាំងអស់គ្នានៅក្នុងតុលាការនេះ ថាមានអង្គហេតុសំខាន់ៗដែលសាក្សីនេះអាចឆ្លើយជូន ដែលអង្គហេតុទាំងអស់នេះមិនមាននៅក្នុងចម្លើយរបស់គាត់មុននោះទេ។ ដូច្នេះ នីតិវិធីតុលាការនៅទីនេះ បានន័យថាយើងបានជួបសាក្សីនេះជាដំបូងនៅក្នុងបន្ទប់សវនាការនេះ។ ហេតុដូច្នេះហើយយើងបានសួរសំណួរទាំងឡាយដែលវាពាក់ព័ន្ធទៅនឹងសាក្សីជាពិសេសអង្គហេតុដែលយើងបានដឹង។

[០៩:០៤:៥០]

ចំពោះអង្គហេតុបន្ថែមដែលលេចចេញកាលពីម្សិលមិញនោះគឺថា យើងខ្ញុំ-- តម្រូវឲ្យយើងខ្ញុំទទួលបានពេលវេលាបន្ថែម ដើម្បីឲ្យយើងខ្ញុំនេះសួរឲ្យសាក្សីនេះផ្តល់អង្គហេតុលម្អិតបន្ថែមទៀត។ ចំណុចដែលគាត់បានឆ្លើយនោះ គឺគាត់នៅជិត កុយ ធួន ហើយគាត់បានបញ្ជាក់ហើយថា គាត់បានរស់

នៅជាមួយ កុយ ធួន ប្រហែលជាដប់ឆ្នាំ។ សាក្សីក៏បញ្ជាក់ផងដែរថា គាត់បានមកដល់ភ្នំពេញនៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ៧៥។ ដូច្នេះហើយ គឺគាត់បានឃើញនូវការជម្លៀសប្រជាជនមួយផ្នែកដែរ។ ភស្តុតាងដែលគាត់បានផ្តល់ជូននោះ គឺគាត់ក៏នៅកៀកនឹង ប៉ង់ ហើយគាត់ក៏បាននិយាយថា ប៉ង់ ជាអ្នកនាំគាត់ចូលបដិវត្តន៍។

[០៩:០៥:៤៥]

ចំណុចចុងក្រោយ យើងឃើញមានបញ្ហាជាច្រើនទៀត អង្គហេតុជាច្រើនទៀតផងដែរ ដែលក្នុងនោះគាត់បានរៀបរាប់ ថាតើគាត់នៅជាមួយនឹង កុយ ធួន យ៉ាងម៉េច ក្នុងរយៈកាលទាំងមូលនោះ មុនពេលដែល កុយ ធួន ត្រូវបានគេចាប់ខ្លួន រួមទាំងនៅច្រាំងចំរេះផងដែរ? អង្គហេតុទាំងអស់នេះហើយមិនមានសរសេរនៅក្នុងការស្តាប់ចម្លើយមុននោះទេ។ យើងខ្ញុំមិនមែនស្នើថា សាក្សីនេះមិនស្មោះត្រង់នោះទេ គ្រាន់តែចំណុចទាំងអស់នេះមិនបានសួរលម្អិតកាលពីលើកមុន។

អង្គហេតុទាំងអស់នេះបានលេចចេញមក ដូច្នេះហើយយើងដឹងថា អង្គហេតុទាំងអស់នេះគឺសាក្សីបានដឹង។ យើងខ្ញុំគិតថា យើងទាំងអស់គ្នាគួរតែដេញដោល និងសួរគាត់ទៅលើចំណុចទាំងអស់នេះ។ ពាក់ព័ន្ធទៅនឹងពេលវេលាបន្ថែម យើងនឹងព្យាយាមឲ្យមានការកម្រិតពេលវេលារបស់យើងតាមដែលអាចធ្វើទៅបាន ហើយយើងនឹងបញ្ចប់មុនពេលអាហារថ្ងៃត្រង់។ យើងខ្ញុំដឹងថា ខាងតំណាងដើមបណ្តឹងរដ្ឋប្បវេណីគាត់ត្រូវការពេលវេលាប្រហែលជាមួយម៉ោង ហើយយើងខ្ញុំសូមអរគុណគាត់ចំណុចហ្នឹងដែរ។ យើងដឹងហើយថា ពេលវេលាបីភាគបួននៅថ្ងៃនេះ ប្រហែលជាយើងខ្ញុំគិតពិចារណា ហើយយើងខ្ញុំសូមអរគុណផងដែរ ចំពោះពេលវេលាដែលបានផ្តល់យើងខ្ញុំ-- ផ្តល់ជូនយើងខ្ញុំ។

[០៩:០៧:១២]

មេធាវីការពារក្តីកាលពីម្សិល គឺគាត់បានឯកភាពថា យើងគួរតែមានភាពបត់បែនទៅលើចំណុចនេះ។ ដូច្នេះហើយយើងខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះពិចារណាទៅលើចំណុចនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធានជាទីគោរព លោក លោកស្រីចៅក្រមជាទីគោរព! យើងគាំទ្រសំអាងហេតុរបស់សហព្រះរាជអាជ្ញា។ ចំពោះយើងៗត្រូវការយ៉ាងហោចណាស់មួយម៉ោង ហើយល្អបំផុតនោះគឺថាមួយ

ម៉ោងកន្លះ។ ដូច្នេះខ្ញុំសូមឲ្យពន្យារពេលដល់សហព្រះរាជអាជ្ញា ក៏ប៉ុន្តែមិនត្រូវកាត់បន្ថយពេលវេលាខាងដើមបណ្តឹងរដ្ឋប្បវេណីទេ។

[០៩:០៨:០៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សួស្តីអស់លោក លោកស្រី។ ទោះបីជាសហព្រះរាជអាជ្ញា គាត់បានលើកឡើងទៅលើចំណុចហ្នឹងក៏ដោយ គឺយើងខ្ញុំគិតថា យើងខ្ញុំមិនជំទាស់ទៅលើពេលវេលាដែលបានស្នើសុំបន្ថែមនេះទេ។ ហើយខ្ញុំគិតថាចំណុចនេះគួរតែអនុវត្តដូចគ្នាចំពោះខ្ញុំដែរនាពេលថ្ងៃខាងមុខ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ម៉ែខល កាណាវាស!

[០៩:០៨:៤៧]

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម អស់លោក លោកស្រីនៅក្នុងបន្ទប់សវនាការ និងជុំវិញបន្ទប់សវនាការ។ សហព្រះរាជអាជ្ញាគាត់បានលើកឡើងជាសង្ខេបអំពី កុយ ធួន ហើយក៏បាន-- សាក្សីគាត់ក៏លើកឡើងអំពី កុយ ធួន និង ប៉ង់។ យើងខ្ញុំជឿជាក់ថាចម្លើយដែលបានឆ្លើយនេះ គឺវាបានបង្ហាញជូនមេធាវីការពារក្តី។ ហើយយើងដឹងហើយថា សាក្សីគាត់មិន-- គាត់បានឆ្លើយទៅលើចំណុចទាំងអស់នេះ ទោះបីជាមិនលម្អិតក៏ដោយ យើងដឹងហើយថា ចំពោះការជម្លៀសទីក្រុងភ្នំពេញនោះគឺវាជាអង្គហេតុមួយថ្មី។ នៅពេលដែលយើងមើលចម្លើយដែលសាក្សីនេះបានឆ្លើយ នៅពេលដែលយើងជាមេធាវីការពារក្តីពិនិត្យមើលចម្លើយនេះ គឺសាក្សីបានលើកឡើងថា នៅពេលដែលគាត់មកដល់ភ្នំពេញនោះ គាត់អាចទំនងជាឃើញនូវការជម្លៀសប្រជាជន ឬក៏នៅពេលដែលគាត់មកជាមួយនឹងក្រុមទាហាននៅថ្ងៃ១៧ មេសា ៧៥ នោះគឺគាត់បានឃើញហេតុការណ៍ទាំងអស់នេះ។

ដូច្នេះ ចំពោះករណីទាំងអស់នេះហើយ យើងខ្ញុំសូមឲ្យអង្គជំនុំជម្រះមានភាពបត់បែនទៅដល់សហព្រះរាជអាជ្ញា ហើយនៅពេលអនាគតនោះ គឺថាគួរតែសហព្រះរាជអាជ្ញានោះបង្ហាញភាពបត់បែន

ដូច្នេះឲ្យខាងមេធាវីការពារក្ដីផងដែរ។ ចំណុចមួយទៀត វាបង្ហាញឲ្យយើងឃើញថា ប្រសិនបើសហព្រះរាជអាជ្ញាទទួលបានពេលវេលាបន្ថែម ហើយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទទួលបានពេលវេលាបន្ថែមនោះ សហព្រះរាជអាជ្ញាក៏មិនទំនងបញ្ចប់ការស្ដាប់សក្ខីកម្ម យើងក៏មិនបញ្ចប់ការស្ដាប់សក្ខីកម្មសាក្សីរូបនេះនៅក្នុងថ្ងៃផងដែរ។ យើងខ្ញុំស្នើសុំថា តើអង្គជំនុំជម្រះនោះ គួរតែបន្តសវនាការនៅថ្ងៃស្អែក ឬក៏យើងត្រូវតែនាំសាក្សីរូបនេះមកសាជាថ្មីម្ដងទៀត? យើងគិតថាវាជាការល្អ ប្រសិនបើយើងបន្តនីតិវិធីនៅថ្ងៃស្អែក ដើម្បីស្ដាប់សាក្សីរូបនេះ។ វាជាការល្អ ងាយស្រួលសម្រាប់ភាគី សម្រាប់សាក្សី ហើយវាមិនចាំបាច់ឲ្យយើងបន្តទៅអាទិត្យក្រោយ។យើងខ្ញុំមិនជំទាស់ទៅនឹងការបើកសវនាការបន្តនៅថ្ងៃស្អែកនោះទេ។ សូមអរគុណ។

[០៩:១១:១៧]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកមេធាវីជាតិការពារក្ដីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទយល់ឃើញ-- មិនមានអ្វីជំទាស់ចំពោះសំណើសុំពេលវេលាបន្ថែមរបស់សហព្រះរាជអាជ្ញាទេ ក៏ប៉ុន្តែខ្ញុំសូមឲ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណាទៅលើតថាភាពរបស់សាក្សីថាតើសាក្សីនេះ បាននាំអ្វីថ្មីសម្រាប់សវនាការនេះ ឬមួយក៏អ្វីដែលសាក្សីនឹងបង្ហាញនេះវាជារឿងដដែលៗ ដែលពុំមានអ្វីថ្មីទេ។ ដែលជាកត្តាមួយដែលអាចថា ការសុំពេលវេលានោះវាមិនចាំបាច់។

[០៩:១១:៥៧]

ទីពីរ ទាក់ទងទៅនឹងការប្រើប្រាស់ពេលវេលា បើសិនជាសហព្រះរាជអាជ្ញាលើកនូវអ្វីដែលថ្មី វាអាចធ្វើឲ្យប៉ះពាល់ទៅដល់ភាគីការពារ ទាំងក្នុងករណីរបស់លោក ខៀវ សំផន។ អ៊ីចឹងការប្រើប្រាស់ពេលវេលារបស់យើងខ្ញុំក៏ត្រូវអាចនឹងត្រូវការពេលវេលាបន្ថែមទៀតដែរ។ ម្យ៉ាងទៀត ទាក់ទងទៅនឹងសំណើរបស់លោកមេធាវីការពារ អៀង សារី លើកអំពីការប្រើប្រាស់ថ្ងៃសុក្រ ខ្ញុំយល់ឃើញថាពេលវេលាសវនាការវាមិនមែនមានន័យថា ត្រូវបញ្ចប់នៅថ្ងៃសុក្រនេះ វាត្រូវបញ្ចប់ទេ វានៅតៗរហូត។ ហើយម្យ៉ាងទៀត យើងឃើញថា អ្នកដែលចូលរួមនៅក្នុងនេះ ជាពិសេសគឺខាងភាគីជនជាប់ចោទនេះ យើងឃើញថា គាត់ក៏ភាពចាស់ជរារបស់គាត់ច្រើន អ៊ីចឹងបើកាលណាបន្តសវនាការជាប់រហូតពេកក៏មិនមានពេលសម្រាកគ្រប់គ្រាន់អាចប៉ះពាល់ដល់សុខភាពរបស់គាត់ដែរ។ អ៊ីចឹងសូមលោកប្រធានមេត្តា

ពិចារណាលើចំណុចនេះផងបាទ។ សូមអរគុណ។

[០៩:១៣:០២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ក្រោយពីបានស្តាប់សំណើសុំរបស់ភាគីតំណាងសហព្រះរាជអាជ្ញាពីការបន្ថែមពេលវេលាសម្រាប់សួរដេញដោលសាក្សី ហើយមានបង្ហាញនូវហេតុផល នូវទឡ្ហីករណ៍មួយចំនួនដែលផ្ទុះបញ្ចាំងអំពីតម្រូវការពេលវេលាបន្ថែមក្នុងការសួរដេញដោលសាក្សីរូបនេះ ដោយការសួរដេញដោល ការស្តាប់ការផ្តល់សក្ខីកម្មរបស់គាត់នៅចំពោះមុខអ្នកស៊ើបអង្កេតកន្លងមកនេះ ឃើញថាមានភាពខុសគ្នារវាងអ្វីដែលគាត់បានមានលទ្ធភាពក្នុងការផ្តល់សក្ខីកម្មជាក់ស្តែងនៅក្នុងបន្ទប់សវនាការ។ ហើយមេធាវីផ្សេងទៀតក៏ ជាពិសេសមេធាវីការពារក្តីក៏មិនជំទាស់ខ្លាំងក្លាលើបញ្ហានេះដែរ។ ដោយសារៈសំខាន់នៃបញ្ហាសាក្សីនេះដែលនឹងអាចមានប្រយោជន៍នៅក្នុងការផ្តល់ព័ត៌មានផ្សេងៗដល់អង្គជំនុំជម្រះ ក្នុងការស្វែងរកការពិត អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាក្នុងការផ្តល់ពេលវេលាឲ្យគាត់សួរសាក្សី ពាន ឃាន នេះ គឺពេញមួយព្រឹកនេះ។បញ្ហាទីពីរ គឺលើ-- យ៉ាងម៉េចទៅលោកមេធាវី?

[០៩:១៤:២០]

**លោក គង់ សំអុន៖**

មុនលោកប្រធានសម្រេច ខ្ញុំបាទសូមបន្ថែមព័ត៌មានបន្តិច ព្រោះលោក ខៀវ សំផន មានការណាត់ជួបជាមួយពេទ្យនៅថ្ងៃស្អែកនេះបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះដូចជាបានជម្រាបជូនម្សិលមិញហើយ ព័ត៌មានអ្វីៗភាគីត្រូវផ្តល់ឲ្យសព្វគ្រប់ យើងបានផ្តល់ពេលវេលាឲ្យភាគីនឹងនិយាយ ថ្ងៃនេះយើងអត់បានកោះហៅសាក្សីមកចំពោះមុខយើងទេ ដោយថាមានសំណើសុំ និងមានបញ្ហាជំទាស់ ឬក៏មានការបញ្ចេញមតិយោបល់ពីភាគីនានា។ ផ្ទុយទៅវិញ ពេលដែលយើងឈានដល់ការសម្រេចៗបានពាក់កណ្តាលហើយ ឥឡូវមកលើក-- ងើបដដែលទៀត។ ស្ថានភាពនេះ យើងបាននិយាយអំពីម្សិលមិញរំឭកម្តងទៀតហើយ ហើយបែបជានៅតែមានស្ថានភាពនេះដដែលៗរបៀបនេះទៀត។ ការប្រព្រឹត្តបែបនេះក៏មិនអាចទទួលយក

បានទេ។ សូមអញ្ជើញមានបញ្ហាអីទៀតទៅ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ដោយសង្ខេប លោកប្រធាន ខ្ញុំគ្រាន់តែចង់ដឹងមុន ថាលោកខាងចៅក្រមឱ្យខាងសហព្រះរាជអាជ្ញាមួយព្រឹកនេះ តើយើងរសៀលនេះ យើងធ្វើយ៉ាងម៉េចទៀត? ដោយខាងដើមបណ្ដឹងរដ្ឋប្បវេណីហ្នឹង ទទួលបានរយៈពេលប៉ុន្មានលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

មិនមានអ្វីប្រែប្រួលទេ។ លោកស្រីសុំមួយម៉ោងជាង ទំនងជាបានមួយម៉ោង គឺវគ្គទីមួយដំបូងនៃដំណើរការសវនាការរសៀលនេះ សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីហើយ យើងមិនមានការដកសិទ្ធិមិនឱ្យសួរដេញដោលទេ។

[០៩:១៦:១១]

អ្វីដែលអង្គជំនុំជម្រះមិនសម្រេច បានន័យថា ត្រូវផលប្រយោជន៍ពីហ្នឹង ពីអ្វីដែលបានបែងចែករួចហើយ នៅពេលវេលាសម្រាប់ភាគីដែលពាក់ព័ន្ធ ឬក៏ចង់សុំមួយថ្ងៃ ឬក៏ពីរថ្ងៃ លោកស្រីអត់បានស្នើសុំអីចឹងទេ។ គ្រាន់តែសុំស្ថានភាពដដែល ទំនងជាត្រូវការចំណាយពេលវាមួយម៉ោង។ យើងគិតថាដើមបណ្ដឹងរដ្ឋប្បវេណីទទួលបានមួយម៉ោងដប់នាទី តាមដំណើរការសវនាការសព្វថ្ងៃនេះ គឺម៉ោងទីមួយគឺមួយម៉ោងដប់នាទីសម្រាក ហើយម៉ោងទីពីរ មានតែមួយម៉ោងទេ។

[០៩:១៦:៤៧]

ដោយឡែកបញ្ហាដំណើរការសវនាការនៅថ្ងៃស្អែក ថាធ្វើ ឬក៏មិនធ្វើនោះ អង្គជំនុំជម្រះនឹងជម្រាបជូនភាគីនៅរសៀលនេះ អាស្រ័យទៅលើស្ថានការណ៍ ថាតើអាចដំណើរការប្រព្រឹត្តទៅបាន ឬក៏មិនបាន? តើមានបញ្ហាឧបសគ្គអ្វីខ្លះ ដែលនាំអង្គជំនុំជម្រះមិនអាចដំណើរការបាននៅព្រឹកថ្ងៃស្អែក។ ឧទាហរណ៍ ឥឡូវនេះ គឺមេធាវីបានលើកឡើងអំពីបញ្ហា ខៀវ សំផន ត្រូវ--មិនមានលទ្ធភាពក្នុងការចូលរួមសវនាការទេ ដោយត្រូវពិនិត្យសុខភាពរបស់គាត់នៅមន្ទីរពេទ្យ ឬក៏នៅកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃស្អែកនេះ ពេលវេលាវាមិនអាចប្រមើលមើលថានឹងអាចចប់បានទេ។ ចៀសវាងថា ក្នុងការអញ្ជើញសាក្សីរូបនេះ មកនៅសប្ដាហ៍ក្រោយ ឬក៏សប្ដាហ៍បន្ទាប់ទៀត ពេលណាមួយហ្នឹង មកបន្តកិច្ចដំណើរការនីតិវិធីមិនបាន គឺដាច់ខាត គឺយើងត្រូវតែធ្វើដូច្នេះហើយ។ លើកលែងតែយើងអាចជម្នះបានបានយើងជម្នះធ្វើឱ្យបាននៅថ្ងៃសុក្រ។

[០៩:១៧:៤៦]

ដូច្នេះ បញ្ហាថ្ងៃសុក្រនេះ យើងមិនទាន់សម្រេចឲ្យបានជាក់ច្បាស់ទេ។ អាស្រ័យលើលទ្ធភាពនៃការដេញដោលនៅរសៀលនេះ ហើយលទ្ធផលបានយ៉ាងដូចម្ដេច។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី និងមេធាវីប្រឹក្សារបស់គាត់ចូលមកកាន់បន្ទប់សវនាការកន្លែងផ្ដល់សក្ខីកម្ម។

*(សាក្សី និងមេធាវីប្រឹក្សាចូលក្នុងបន្ទប់សវនាការ)*

[០៩:១៩:១៦]

**ប្រធានអង្គជំនុំ៖**

អរុណសួស្ដី លោក ពាន ឃាន។ តាមព័ត៌មានដែលអង្គជំនុំជម្រះទទួលបាននេះ គឺថាលោកមានបញ្ហាសុខភាពបន្តិចបន្តួចដែរ នៅព្រឹកនេះ។ តើពិតអ៊ីចឹងមែនទេ?

**លោក ពាន ឃាន៖**

បាទ ពិតអ៊ីចឹងមែន។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ លោកមានលទ្ធភាពអាចផ្ដល់សក្ខីកម្មបានទេ នៅសម្រាប់ថ្ងៃនេះ?

**លោក ពាន ឃាន៖**

ខ្ញុំនឹងខំប្រឹងប្រែងឲ្យអស់លទ្ធភាព។

[០៩:១៩:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើនចំពោះការផ្ដល់ព័ត៌មាននេះ ដើម្បីអង្គជំនុំជម្រះនឹងអាចដំណើរការសម្របសម្រួលនៅក្នុងការដេញដោលចំពោះលោកទាំងពេលវេលា ក៏ដូចជាបញ្ហាជាក់ស្ដែងនៃអាកប្បកិរិយារបស់លោក នៅពេលដែលស្ថានភាព សុខភាព ជួបប្រទះបញ្ហាដូច្នេះ។ ហើយក្នុងករណីដែលលោកមានបញ្ហាធ្ងន់ធ្ងរមិនអាចបន្តការផ្ដល់សក្ខីកម្មបាន សូមលោកផ្ដល់ ជម្រាបមកយើង ដើម្បីឲ្យយើងអាចសម្រាកបណ្ដោះអាសន្ន ឬក៏អាចសម្រាកលើកទៅពេលក្រោយតាមស្ថានភាពជាក់ស្ដែង។ ស្ដាប់បានទេ?

**លោក ពាន ឃាន៖**

បាទ ស្ដាប់បាន អរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ហើយសូមព្រះរាជអាជ្ញារៀបចំនូវការសំណួរ ដោយជ្រើសរើសយកសំណួរសក្តានុពល ហើយដែលសំណួរសារធាតុដែលពាក់ព័ន្ធនឹងអង្គហេតុជាក់ស្តែង ដើម្បីប្រើប្រាស់ពេលវេលាដែលចែកឲ្យហ្នឹងឲ្យមានប្រសិទ្ធភាពខ្ពស់។ ហើយសូមចាប់អារម្មណ៍ផងដែរថា សាក្សីគាត់មានបញ្ហាសុខភាពបន្តិចបន្តួចនៅវសៀលនេះ អ៎ នៅៗពេល នៅចំពោះមុខយើងនៅពេលនេះ ហើយគាត់ប្រឹងប្រែងផ្តល់សក្ខីកម្មទេ។ ដូច្នេះការតាំងសំណួរគួរតែត្រូវបានធ្វើឲ្យភាពងាយស្រួល ខ្លីដើម្បីឲ្យងាយស្រួលដល់សាក្សីស្តាប់យល់ ហើយនិងអាចឆ្លើយតបបាន។

តំណាងសហព្រះរាជអាជ្ញាអង្គុយចុះសិន!

សូមអញ្ជើញលោកមេធាវីជាតិការពារក្តី នួន ជា!

[០៩:២១:៤៣]

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន សូមអរគុណ។ ខ្ញុំសូមបញ្ជាក់ ពីរឿងឈ្មោះពីម្សិលមិញសាក្សីបាននិយាយថា គាត់ធ្វើការជាមួយនឹង កុយ ឃួន ហើយសហព្រះរាជអាជ្ញាបានសួរបញ្ជាក់ទៀតថា កុយ ធួន ឬ កុយ ឃួន? បើតាមឯកសារពីមុនមកច្រើនទាំងអស់នៅក្នុងតុលាការ មានឈ្មោះតែ កុយ ធួន ទេមិនមែន កុយ ឃួន ដូចសាក្សីគាត់មានបានប្រកាសហ្នឹងទេ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ពេលគេ តំណាងសហព្រះរាជអាជ្ញាសួរ ហើយដល់ពេលវេនលោក លោកអាចសួរបញ្ជាក់ ហើយលោកសួរបញ្ជាក់ទៅមនុស្សពីរហ្នឹងគឺថាវាមានមនុស្សខុសគ្នាហ្នឹង គឺជារឿងមួយផ្សេងទៀត អង្គជំនុំជម្រះនឹងពិចារណាហើយ។ បានហើយ!

អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា!

[០៩:២២:៤៦]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន សូមអរគុណលោក លោកស្រីចៅក្រម ដែលអនុញ្ញាតផ្តល់ពេលវេលាបន្ថែមជូនយើងខ្ញុំ។ ហើយសូមអរគុណមេធាវីការពារក្តីទាំងអស់ ដែលបានសម្របសម្រួលចំណុច

ទាំងអស់នេះ។ ហើយយើងខ្ញុំនឹងព្យាយាមធ្វើការផ្តល់នូវការបត់បែនជូនអស់លោក លោកស្រីតាមដែលអាចធ្វើទៅបានដូចគ្នា។

សូមអរគុណលោក ពាន ឃាន ដែលលោកត្រឡប់មកផ្តល់សក្ខីកម្មឡើងវិញនៅពេលនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** យើងនឹងបន្តការសួរសំណួររបស់យើងខ្ញុំបន្តទៀត ចាប់ផ្តើមពីចំណុចដែលយើងឈប់កាលពីម្សិលមិញ។ លោកបានជម្រាបជូនយើងខ្ញុំថា មុនពេលដែលលោកឈប់ផ្តល់ចម្លើយកាលពីម្សិលមិញ លោកបានឆ្លើយថា កុយ ធួន ត្រូវបានគេចាប់ខ្លួន ហើយយកទៅដាក់កន្លែង៣០០ម៉ែត្រ នៅក-១ តើអ៊ីចឹងដែរឬទេ?

**លោក ពាន ឃាន៖**

**ឆ៖** បាទ តាមក្នុងពេលនោះ គឺអ៊ីចឹងមែន។

[០៩:២៣:៥៧]

**ស៖** សូមអរគុណ។ ខ្ញុំដឹងថា អង្គហេតុនេះកើតឡើងយូរមកហើយ ក៏ប៉ុន្តែតើលោកអាចរម្លឹកឡើងវិញដែរឬទេ? តើការចាប់ខ្លួននោះកើតឡើងនៅពេលណាដែរ ក្រោយបក្សកុម្មុយនីស្តកម្ពុជាចូលមកទីក្រុងភ្នំពេញហ្នឹង គឺក្រោយរយៈពេលប៉ុន្មានឆ្នាំដែរ ទើបមានការចាប់ខ្លួនគាត់នោះ?

**ឆ៖** តាមខ្ញុំចាំ គឺចុង៧៥ ចូល៧៦ បានចាប់ខ្លួនលោក កុយ ឃួន។

**ស៖** សូមអរគុណ។ តើលោកអាចរៀបរាប់លោកក្រុមប្រឹក្សាអង្គជំនុំជម្រះដែរឬទេ កន្លែងដែលគេឃុំគាត់? លោកលើកឡើងហើយថា ៣០០ម៉ែត្រពីកន្លែងនោះ តើលោកអាចរៀបរាប់ទីតាំងនោះយ៉ាងម៉េចដែរ?

**ឆ៖** ទីតាំងនៅកន្លែងនោះមានដូចសណ្ឋាគារមួយអ៊ីចឹង ហើយគេព័ទ្ធស័ង្កសីជុំវិញ ហើយព្រមទាំងមានលួសបន្លាពីលើថែម។ ហើយកន្លែងនោះឃើញៗតែគាត់តែម្នាក់គាត់ទេ អត់មានអ្នកណាទាំងអស់។ ហើយខ្ញុំទៅហ្នឹងក៏មិនយូរ មួយភ្លែត ហើយខ្ញុំប្រគល់មាន់ឲ្យគាត់ហើយអីហើយ ខ្ញុំមកវិញ មកក-១ វិញ។

**ស៖** តើលោកដឹងថាគាត់ត្រូវបានគេឃុំខ្លួននៅកន្លែងដែលថាស្រដៀងអូតែលហ្នឹង ដឹងដោយរបៀបណាដែរ?

[០៩:២៦:១០]

**ឆ៖** កន្លែងហ្នឹង ខ្ញុំ-- ព្រោះខ្ញុំចេញពី ក-១ ហ្នឹង ខ្ញុំទៅឆៀងខាងត្បូងពី ក-១ ប្រហែលជាជាង ៣០០ម៉ែត្រចុះ។ ហើយទៅដល់កន្លែងគាត់ហ្នឹង។ ប៉ុនខ្ញុំមិនចាំថាកន្លែងហ្នឹងជាកន្លែងអីទេ។ ខ្ញុំអត់ស្គាល់ដែរ។

**ស៖** ក៏ប៉ុន្តែលោកបានជម្រាបជូនយើងខ្ញុំថា គាត់ត្រូវបានគេឃុំខ្លួន។ តើមានអ្នកយាមកាមដែរឬទេ? ហើយគេឃុំគាត់ហ្នឹង ឃុំដោយរបៀបណាដែរ ឃុំយ៉ាងម៉េចដែរ?

**ឆ៖** ពេលខ្ញុំចូលទៅដល់កន្លែងហ្នឹង អត់ឃើញមានអ្នកណាជាឆ្មាំ ឬក៏ជាកងការពារអីទេ ប៉ុនចូលទៅដល់ឃើញគាត់កំពុងអង្គុយលើបង់ហ្នឹង ហើយខ្ញុំក៏សួរសុខទុកតិចតួច ហើយឲ្យមាន់ទៅគាត់ទៅក៏ខ្ញុំត្រឡប់មកវិញ។

**ស៖** តើនៅពេលនោះលោកមាននិយាយជាមួយគាត់ដែរឬទេ?

**ឆ៖** ពេលនោះគ្រាន់តែសាកសួរសុខទុក្ខរបស់គាត់តែពីរបីមាត់តែប៉ុណ្ណោះ។ មិនបាននិយាយអីវែងឆ្ងាយទេ។

[០៩:២៨:១៤]

**ស៖** តើអ្នកណាគេដែលស្នើឲ្យលោក ចាត់តាំងឲ្យលោកយកម្ហូបអាហារទៅឲ្យគាត់នោះ?

**ឆ៖** គឺឈ្មោះ ប៉ង់ អ្នកឲ្យយកទៅ។

**ស៖** តើ ប៉ង់ មាននិយាយជាមួយលោកថាមានអ្វីកើតឡើងចំពោះ កុយ ធួន នៅពេលនោះដែរឬទេ?

**ឆ៖** គាត់មិនបាននិយាយអីទាំងអស់ គ្រាន់តែប្រាប់ខ្ញុំថាឥឡូវ ឃាន ឯងយកមាន់ហ្នឹងទៅឲ្យ កុយ ឃួន មួយភ្លែត ហើយមកវិញទៅ។ គាត់ណែនាំខ្ញុំបានតែប៉ុណ្ណឹង។

**ស៖** លោក ពាន ឃាន ខ្ញុំចង់បង្ហាញរូបថតបីបួន ហើយចង់សាកសួរលោក ថាតើលោកស្គាល់អ្នកណាខ្លះនៅក្នុងរូបថតទាំងអស់នេះ ដើម្បីបង្ហាញជូនអង្គជំនុំជម្រះ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំ យើងខ្ញុំសូមការអនុញ្ញាតដើម្បីបញ្ចាំងនៅលើអេក្រង់ ឯកសារលេខ D313/1.2.237, D313/1.2.237 វាជារូបថតបង្ហាញបុគ្គលមួយចំនួននៅក្នុងនេះ។ ខ្ញុំក៏មានឯកសារជាក្រដាសផងដែរ។ ប្រហែលជាយើងអាចបញ្ចាំងនៅលើអេក្រង់ ហើយខ្ញុំអាចផ្តល់ឯកសារនេះជាក្រដាស

ជូនលោកសាក្សី ដើម្បីឲ្យគាត់ងាយស្រួលមើលតែម្តង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សីពិនិត្យ!

[០៩:៣០:៣៥]

*(មន្ត្រីរដ្ឋបាលតុលាការយកឯកជូនសាក្សី)*

**លោក អាប់ឌុលឡាក់ ថាវីក៖**

ខាងសោតទស្សន៍អាចជួយចាក់បញ្ចាំងរូបថតនេះនៅលើអេក្រង់ផង។

សូមអរគុណច្រើន។

**សួរដោយលោក អាប់ឌុលឡាក់ ថាវីក៖**

**ស៖** លោក ពាន ឃាន រូបថតនៅលើអេក្រង់នេះ គឺដូចទៅនឹងរូបថតដែលខ្ញុំបានផ្តល់ជូនលោកមួយអម្បាញ់មិញនេះ។ ដូច្នេះហើយលោកអាចមើលអេក្រង់ក៏បាន ឬក៏មើលក្រដាសក៏បានដែរ មួយណាប្រសិនបើស្រួលសម្រាប់លោក លោកអាចមើលបាន។ នៅពេលដែលលោកមើលរូបថតនេះ តើលោកស្គាល់មនុស្សណាខ្លះ នៅក្នុងរូបថតនេះដែរឬទេ?

*(សាក្សីពិនិត្យមើលរូបថត)*

[០៩:៣២:២៦]

**លោក ពាន ឃាន៖**

**ឆ៖** ក្នុងរូបថតនេះ ខ្ញុំដូចអត់បានស្គាល់ពីណាទេ ឬមួយក៏ខ្ញុំវាភ្លេចយូរហើយក៏មិនដឹង មិនបានចាំ។ ប៉ុន្តែខ្ញុំមើលក្នុងពេលនេះ ខ្ញុំអត់អាចចាំថាស្គាល់មួយណាទេ មិនអាចចាំបាន។

**ស៖** សូមអរគុណ វាជារូបថតមួយចាស់ មានវ័យចំណាស់ផង។

**លោក អាប់ឌុលឡាក់ ថាវីក៖**

លោកប្រធាន ប្រសិនបើលោកប្រធានអនុញ្ញាត ខ្ញុំសូមបញ្ចាំងរូបថតមួយទៀត គឺឯកសារ D108/32.2/P0043 វាជារូបថតមួយសន្លឹកផ្សេងទៀត វាច្បាស់ជារូបថតមួយមុន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងព្រះរាជអាជ្ញាជូនសាក្សីពិនិត្យ។

[០៩:៣៣:៤០]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ពាន ឃាន ខ្ញុំសូមឲ្យរង់ចាំឲ្យរូបថតនេះបញ្ចាំងលើអេក្រង់ជាមុនសិន។ លោក ពាន ឃាន នៅក្នុងរូបនេះ តើលោកស្គាល់អ្នកដែលអង្គុយហ្នឹងដែរឬទេ?

**លោក ពាន ឃាន៖**

**ឆ៖** រូបមួយនេះ ក៏ខ្ញុំដូចមិនដែលឃើញដែរ អត់បានចាំ មិនដឹងឈ្មោះពីណា។

**ស៖** អរគុណ។ លោកបានជម្រាបជូនយើងខ្ញុំថា នៅចុងឆ្នាំ៧៥ ឬក៏ដើមឆ្នាំ៧៦ នៅក្នុងពេលនោះ កុយ ធួន ឬក៏ ធុច នោះត្រូវបានគេចាប់ខ្លួន។ តើលោកដឹងហេតុផលដែរឬទេ? ហេតុអីបានជាគេចាប់គាត់?

**ឆ៖** ក្នុងពេលដំបូង ខ្ញុំមិនដឹងហេតុផលទេ ប៉ុន្តែក្រោយពីចាប់ខ្លួនគាត់ទៅ អង្គការផ្សាយតាមប៉ុស្តិ៍វ៉ាដ្យូថា កុយ ឃួន ក្បត់ផ្ទៃក្នុងខាង សេ.អ៊ី.អា។ ការផ្សព្វផ្សាយឲ្យមហាជនដឹងឮ នៅពេលនោះថា កុយ ឃួន សរសេរសំបុត្រសារភាពឲ្យបក្ស។ ខ្ញុំដឹងតែប៉ុណ្ណឹង។

[០៩:៣៦:១៩]

**ស៖** សូមអរគុណលោក។ នៅពេលដែលគេចាប់ខ្លួន ហើយនិងក្រោយពេលគេចាប់ខ្លួនគាត់នោះ ថាតើមានការចាប់ខ្លួនបុគ្គលដទៃទៀត ដែលធ្វើការនៅក្នុងភូមិភាគរបស់គាត់ ឬក៏នៅក្នុងក្រសួងរបស់គាត់ បើតាមដែលលោកដឹង តើមានការចាប់ខ្លួនអ្នកដទៃទៀតទេ?

**ឆ៖** ខ្ញុំមិនបានដឹង ហើយក៏មិនបានឃើញដែរ។ ប៉ុន្តែចេះតែឮតាមគេតៗគ្នាថា ក្រោយពីចាប់ កុយ ឃួន ជាថ្នាក់ភូមិភាគហ្នឹងហើយ ដូច្នេះភូមិភាគហ្នឹងត្រូវរំលាយ។ បើចាប់មេ កូនចៅត្រូវរំលាយ ហើយនៅក្នុងសាខានោះ អត់ឲ្យមានទេ ត្រូវរៀបចំជាថ្មី។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** ហើយក្នុងបំពេញការងាររបស់លោកនៅពេលនោះ តើលោកមានកត់សម្គាល់ឃើញថា ថាតើមានអ្នកណានៅខាងឧត្តរថ្មីនុ៎ង ខាងៗភូមិភាគថ្មីហ្នឹងមានបាត់ខ្លួនដែរឬទេ? តើលោកមានឃើញអ្នកណាបាត់ខ្លួនដែរឬទេ?

**ឆ៖** ក្រោយពេលនោះ ខ្ញុំអត់បានដឹងទាំងអស់ ព្រោះអីខ្ញុំនៅ ក-១ ជាកន្លែងចង្អៀត ខ្ញុំមិនអាចដឹងបានទេ។

**ស៖** ហើយខ្ញុំមានសំណួរពីរបីទៀតទាក់ទងទៅនឹង ឌុច។ លោកនិយាយថា លោករស់នៅជាមួយគាត់រហូតដល់ពេលដែលគេចាប់ខ្លួនគាត់។ តើលោកធ្លាប់និយាយពិភាក្សាជាមួយគាត់អំពីការងាររបស់គាត់ដែរឬទេ?

**ឆ៖** គាត់មិនដែលណែនាំ ឬក៏បង្ហាញអ្វីមួយចំពោះខ្ញុំទេ។ ការងារគាត់ ខ្ញុំគ្រាន់តែដឹងគាត់ជាតំណាងភូមិភាគ៣០៤ តែប៉ុណ្ណោះ។ អ្វីផ្សេងទៀត ខ្ញុំអត់ដឹង អត់បានឮ។

[០៩:៣៩:១០]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាសូមលោកចាប់អារម្មណ៍។ អម្បាញ់មិញនេះតំណាង-- ក្រុមមេធាវីការពារក្ដីលោក នួន ជា ក៏គេបានលើកឡើងដែរ។ សាក្សីគាត់បានស្គាល់ កុយ ឃួន ហើយការប្រើពាក្យពេចន៍ក្នុងការតាំងសំណួរ លោកអត់បានសួរដេញដោលពីរឿង កុយ ឃួន និង កុយ ធួន ហ្នឹងជាមនុស្សតែម្នាក់ ឬក៏មនុស្សដោយឡែកពីគ្នាទេ។ សំណួរនេះសាក្សីអត់ទាន់បានដឹងទេ។ ទីពីរថា កុយ ឃួន ហ្នឹងហៅ ធុច ក៏ទំនងជាមិនទាន់បានសួរដែរ។ វាត្រូវតែរំលេចឲ្យបានច្បាស់លាស់ ថាតើ កុយ ឃួន ហ្នឹងមានឈ្មោះផ្សេង ហៅក្រៅផ្សេងទៀតទេ លុះត្រាតែសាក្សីហ្នឹងស្គាល់ថា កុយ ឃួន ហ្នឹងហៅឈ្មោះផ្សេងទៀត ដែលមានឈ្មោះហៅក្រៅមួយទៀត អាហ្នឹងគួរតែប្រើប្រាស់ឈ្មោះផ្សេងទៀត។ ហើយចៀសវាងការប្រើប្រាស់នូវឈ្មោះផ្សេងទៀតដែលសាក្សីរូបនេះអត់ទាន់បានស្គាល់ទេ។ គាត់និយាយថាគាត់បានស្គាល់តែឈ្មោះ កុយ ឃួន ទេ។ នេះជាបញ្ហាដែលពាក់ព័ន្ធនឹងខ្លឹមសារទូទៅដែលនឹងអាចសួរដេញដោលជាលទ្ធផលដែលទៅថ្ងៃមុខមេធាវីការពារក្ដីគេនឹងសួរបញ្ហានេះឡើងវិញហើយ។ អ៊ីចឹងលទ្ធផលនៃការដេញដោលនេះវាអាចមានបញ្ហាប្រឈមខ្លាំងក្នុងការវិភាគ ពិចារណារបស់អង្គជំនុំជម្រះ។ បានន័យថា វាអត់ច្បាស់។ បើមិនទាន់ស្គាល់ឈ្មោះផង មនុស្សជាក់លាក់ផង ដល់ពេលសួរដេញដោលទៅលទ្ធផលដែលដេញដោលជុំវិញបញ្ហាហ្នឹងវាអត់ច្បាស់។

[០៩:៤០:៤៣]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ឥឡូវនេះ យើងនឹងបញ្ជាក់ទៅលើបញ្ហានេះឲ្យច្បាស់។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ពាន យាន យើងបាននិយាយយោងទៅលើបុរសម្នាក់ឈ្មោះ កុយ ធួន ហើយលោកបាននិយាយថា លោកបានស្គាល់មនុស្សម្នាក់មួយ កុយ ឃួន ដែលជាលេខាភូមិភាគ៣០៤ ហើយម្សិលមិញលោកបាននិយាយថា មនុស្សហ្នឹងគឺក្លាយជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ បើតាមដែលលោកដឹងថា តើបុគ្គលដែលលោកស្គាល់ថាឈ្មោះ កុយ ឃួន ហ្នឹងមានឈ្មោះហៅក្រៅដទៃទៀតដែរឬទេ?

**លោក ពាន យាន៖**

**ឆ៖** តាមដែលខ្ញុំចាំ ខ្ញុំធ្លាប់ ខ្ញុំឮ ខ្ញុំស្គាល់ហ្នឹង គឺ កុយ ឃួន ហៅ ធុច ហ្នឹងហើយ។ មានតែមួយ អឺ! ឈ្មោះតែពីរហ្នឹង ដែលខ្ញុំតែងតែឮការប្រើប្រាស់រហស្សនាមរបស់គាត់។

[០៩:៤១:៥២]

**ស៖** សូមអរគុណច្រើនលោក។ បើតាមដែលលោកនៅចងចាំបាន ថាតើបុគ្គលដែលលោកហៅថា កុយ ឃួន ហៅ ឌុច*(ស៊ុក)* ហ្នឹង គឺជាមនុស្សតែមួយដូចគ្នានឹង កុយ ធួន តើលោកអាចចាំបានដែរឬទេថា ដូចគ្នា ឬខុសគ្នា?

**ប្រធានអង្គជំនុំ៖**

អ្នកបកប្រែដូចអត់ត្រឹមត្រូវទេណ៎ា! ធុច ហើយ ឌុច ខុសគ្នាឆ្ងាយណាស់អក្សរណ៎ះ! មួយអក្សរ “ឌ” មួយ អក្សរ “ធ” ហើយឈ្មោះមនុស្សណ៎ះ! មិនអាចចេះតែបកប្រែខុស ប្រើខុសទៅវាអត់មានខ្លឹមសារអីទេ ក្នុងការដេញដោលនេះ ត្រូវសួរដេញដោល-- មានន័យថា ដេញដោលមនុស្សផ្សេង។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធានសម្រាប់ការអនុញ្ញាតអន្តរាគមន៍ ដូច្នេះខ្ញុំសូមរំឭកសំណួរឡើងវិញ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ថាតើអាចដែរឬទេ ដែលថាបុគ្គលដែលលោកស្គាល់ថា កុយ ឃួន ហៅ ធុច គឺជាបុគ្គលតែមួយដែលយើងហៅឈ្មោះថា កុយ ធួន?

[០៩:៤៣:២៣]

**លោក ពាន យាន៖**

**ឆ៖** តាមខ្ញុំចាំ ខ្ញុំដឹង ខ្ញុំធ្លាប់ស្គាល់ ឈ្មោះគាត់មានតែ កុយ ឃួន ហៅ ធុច តែប៉ុណ្ណោះទេ។ រឿង ឌុច អីខ្ញុំអត់ដឹងទេ។ ហើយគាត់ឈ្មោះពីរហ្នឹង តែមួយទេ។

**ស៖** សូមអរគុណ។ តើលោកអាចជម្រាបតុលាការបានដែរឬទេ ថាតើមានអ្វីកើតឡើងបន្ទាប់ពីគេនាំខ្លួន ផុច យកទៅ?

**ឆ៖** ក្រោយដែលខ្ញុំបានជួបគាត់ម្តងនោះ តាំងពីនោះមកស្ងាត់អត់ដែលបានជួប អត់ឮដំណឹងទៀតអ្វីទាំងអស់។

**ស៖** យើងយល់អំពីបញ្ហានេះ សូមអរគុណ។ លោកនិយាយថា គាត់បាត់ខ្លួន ឬក៏គេត្រូវចាប់ខ្លួននៅចុង៧៥ ដើម៧៦ តើនៅពេលនោះលោកធ្វើការនៅកន្លែងណាដែរ?

[០៩:៤៥:០០]

**ឆ៖** នៅពេលនោះ ខ្ញុំនៅច្រាំងចំរេះ ផ្ទះគាត់នៅច្រាំងចំរេះ។ ផ្ទះធ្វើការងារ។

**ស៖** សូមអរគុណ។ តើលោកដឹងដែរឬទេ ថាតើមានអ្វីកើតឡើងនៅច្រាំងចំរេះ បន្ទាប់ពី ផុច បានបាត់ខ្លួន ឬក៏ត្រូវបានគេចាប់ខ្លួននោះ? ថាតើមនុស្សនៅច្រាំងចំរេះហ្នឹង គេបន្តរស់នៅទីនោះតទៅទៀត ឬមួយក៏យ៉ាងណាដែរ?

**ឆ៖** ក្រោយពីចាប់ខ្លួនគាត់ ក្នុងអង្គភាពដែលគាត់គ្រប់គ្រងនៅកន្លែងនោះ ត្រូវរំសាយតាមអង្គភាពនានា ហើយក៏ខ្ញុំមិនចាំថាអ្នកណាទៅនៅអង្គភាពណាទេ គ្រាន់តែដឹងថា មានការរំសាយចេញ។

**ស៖** តើលោកដឹងបញ្ហានេះ ដោយរបៀបណា? ថាតើលោកដឹងដោយសារតែលោកបាននិយាយជាមួយអ្នកដទៃ ឬមួយក៏លោកបានឃើញ? តើលោកដឹងដោយរបៀបណាអំពីអ្វីដែលកើតឡើងនៅច្រាំងចំរេះ?

**ឆ៖** ដឹងដោយមិត្តភក្តិគេខ្សឹបប្រាប់ខ្ញុំ។

**ស៖** សូមអរគុណ។ ឥឡូវនេះ តាមតែខ្ញុំចាំ កាលពីម្សិលមិញលោកបាននិយាយ ប្រសិនបើខ្ញុំនិយាយខុស សូមលោកកែខ្ញុំ។ គឺលោកបាននិយាយថា គឺប្រហែលជាពីរខែ ក្រោយ ផុច បាត់ខ្លួន។ នៅពេលនោះ គឺ ប៉ង់ នាំលោកទៅធ្វើការនៅ ក-១ តើខ្ញុំយល់បែបនេះត្រឹមត្រូវដែរឬទេ?

[០៩:៤៧:១៤]

**ឆ៖** បាទ លោក គឺជាត្រឹមត្រូវហើយ។

**ស៖** សូមអរគុណច្រើនលោក។ ថាតើ ក-១ ហ្នឹង នៅកន្លែងណាដែរ?

**ឆ៖** ក-១ នៅជាប់ខាងត្បូងវិមានឯករាជ្យ ជាប់មាត់ទន្លេ។ គឺជាផ្ទះរបស់អ៊ំៗ ប៉ុល ស្នាក់នៅ។

**ស៖** តើនៅពេលដែលលោកហៅ អ៊ំប៉ុល តើសំដៅទៅលើ ប៉ុល ពត មែនទេ?

 E1/72.1

**ឆ៖** បាទ សំដៅទៅលើគាត់។

**ស៖** តើលោកអាចជម្រាបមកតុលាការបានដែរឬទេ ថាតើ ក-១នុំង វាមានលក្ខណៈទ្រង់ទ្រាយរូបរាងបែបណាដែរ មន្ទីរក-១ហ្នឹង?

**ឆ៖** ក-១ ហ្នឹង មានផ្ទះពីរល្វែង។ ទទឹង ល្វែងទទឹង ជើងត្បូងមួយ-- អ៎ បណ្តាយជើងត្បូងមួយ ហើយអាទទឹងលិចកើតមួយ។ ផ្ទះពីរហ្នឹងជាប់គ្នា ក្បែរៗគ្នា។ ហើយក្រៅពីហ្នឹង ជុំវិញគឺមានរបងព័ទ្ធដោយស៊ីម៉ង់ត៍ ហើយនិងស័ង្កសី។ ទីធ្លាហ្នឹង ក៏ចង្អៀតដែរ ប្រហែលជា១០០ម៉ែត្រ បួនជ្រុង។

ខ្ញុំចាំបានតែប៉ុណ្ណឹង។

[០៩:៤៩:៣៥]

**ស៖** សូមអរគុណលោក។ លោកបាននិយាយថា វាមានជញ្ជាំង និងរបងស៊ីម៉ង់ត៍ តើមានសន្តិសុខយាមដែរឬទេ នៅទីនោះ?

**ឆ៖** កាលណោះ ឃើញតែយាមផ្លូវចេញចូលពីវិមានឯករាជ្យចូលមកកន្លែងគាត់ហ្នឹង ឃើញជារោងយាមធម្មតាប្រចាំថ្ងៃ។ យាមម្នាក់ៗអី អង្គុយនៅយាមនៅកន្លែងនោះ។ សូមអស់។

**ស៖** សូមអរគុណលោក។ តើលោកធ្វើអ្វីដែលនៅដែលនៅ ក-១ នោះ ថាតើលោកមានការងារអ្វីដែរនៅ ក-១នោះ?

**ឆ៖** នៅ ក-១ ខ្ញុំរត់ម្ហូបអាហារ ដើររកបន្លែបង្ការសម្រាប់ចុងភៅ ផ្ទះបាយសម្រាប់អ៊ំ ប៉ុល ពត នៅកន្លែងនោះឯង។

[០៩:៥១:១៩]

**ស៖** ខ្ញុំចង់សួរលោកថា តើលោករស់នៅក្នុង ក-១ ឬមួយក៏លោកនៅកន្លែងផ្សេង គឺថាតើលោករស់នៅក្នុង ក-១ ហ្នឹងតែម្តង ឬមួយក៏លោកនៅផ្ទះផ្សេង?

**ឆ៖** ខ្ញុំរស់នៅទីកន្លែងហ្នឹងតែម្តង។

**ស៖** សូមអរគុណ។ បើតាមដែលលោកចាំ តើលោករស់នៅទីនោះរយៈពេលប្រហែលប៉ុន្មានដែរ?

**ឆ៖** តាមខ្ញុំចាំប្រហែលជាកន្លះឆ្នាំដែរ ខ្ញុំនៅធ្វើឯនោះ។

**ស៖** ហើយនៅក្នុងរយៈពេលកន្លះឆ្នាំនោះ តើលោកបានឃើញដោយផ្ទាល់ភ្នែកនូវ ប៉ុល ពត ដែរឬទេ? ហើយថាតើលោកធ្លាប់ឃើញមេដឹកនាំបក្សដទៃទៀតដែរឬទេ?

**ឆ៖** ក្នុងពេលនោះ នៅក្របខ័ណ្ឌអាផ្ទះ ក-១ ខ្ញុំជាអចិន្ត្រៃយ៍ ខ្ញុំឃើញអ៊ំ ប៉ុល ពត ហ្នឹង ហើយនិងអ៊ំ នួន ជា។ ប៉ុនអ៊ំ នួន ជា មក ក-១ ហ្នឹងម្តងមួយកាលទេ។ ជាអចិន្ត្រៃយ៍គឺអ៊ំ ប៉ុល ពត។

**ស៖** សូមអរគុណ។ ដើម្បីធ្វើការបញ្ជាក់បន្ថែមទៀតលោក ពាន ឃាន ខ្ញុំគិតថាព្រឹត្តិការណ៍នេះវាកើតឡើងយូរមកហើយ ប៉ុន្តែខ្ញុំចង់បញ្ជាក់ឲ្យបានលម្អិត ឲ្យបានច្បាស់បន្តិច ថាតើលោកអាចចងចាំបានដែរឬទេ?

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ប្រសិនបើលោកអនុញ្ញាត ខ្ញុំសូមបង្ហាញសាក្សីនូវកិច្ចសម្ភាសន៍របស់គាត់ជាមួយនឹងសហចៅក្រមស៊ើបអង្កេត គឺអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ D276/6 ដើម្បីឲ្យសាក្សីគាត់អាចបញ្ជាក់បំភ្លឺទៅលើចម្លើយរបស់គាត់។ សូមអរគុណ។

[០៩:៥៤:១៦]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាជូនទៅសាក្សីពិនិត្យ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ក្នុងពេលដែលនេះ ខ្ញុំសូមជម្រាបនូវលេខ ERN គឺភាសាខ្មែរដែលមានលេខ 0037348 ចំណែកភាសាបារាំងគឺ 00424123 ហើយនិងភាសាអង់គ្លេសគឺ 00375887។

ដូច្នេះខ្ញុំសូមជម្រាបនូវលេខ ERN ទៅមន្ត្រីតុលាការគឺ 00373448 ជាភាសាខ្មែរ, គឺ ERN ដែលមានលេខ 448 ខាងចុងនៅក្នុងភាសាខ្មែរ ហើយខ្ញុំគឺថាយើងនឹងឃើញនៅលើអេក្រង់កុំព្យូទ័រ។

[០៩:៥៥:៣៣]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សូមអរគុណច្រើនលោក ពាន ឃាន។ ដូចដែលខ្ញុំបានជម្រាបហើយគឺថា យើងសូមឲ្យលោកពិនិត្យមើលទៅលើឯកសារ ដោយទៅមើលអង្គហេតុដែលបានកើតឡើងកាលពីយូរណាស់មកហើយ។ នៅក្នុងនេះ គឺមានសំណួរដែលចោទសួរថា នេះគឺជាកិច្ចសម្ភាសន៍របស់លោក គឺជាការស្តាប់ចម្លើយរបស់លោកជាមួយនឹងអ្នកស៊ើបអង្កេត ហើយសំណួរនេះបានចោទសួរថា “តើលោកដែលឃើញមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមណាទៅទីនោះទេ?” ហើយលោកបានឆ្លើយថា “ខ្ញុំមិនដែលឃើញអ្នកដឹកនាំ

ណាចេញចូលទីនោះទេ មានតែប្រធានមន្ទីរឈ្មោះ ប៉ង់។ ក-១ មិនមែនជាកន្លែងប្រជុំទេ"។ ហើយបន្ទាប់មកទៀត លោកបាននិយាយថា "ជាទូទៅគេប្រជុំនៅកន្លែងចល័ត ក-៣"។

លោកទើបតែបានជម្រាបយើងថា លោកបានឃើញលោក នួន ជា នៅ ក-១។ ដូច្នេះ ខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យបានច្បាស់ ថាតើលោកចាំបានត្រឹមត្រូវដែរឬទេ អ្វីដែលលោកបាននិយាយមុននេះ? ថាតើលោកបានឃើញអ្នកណានៅពេលនោះ ប្រសិនបើលោកមិនចាំច្បាស់ទេ លោកអាចជម្រាបយើង ដូច្នេះ អត់មានបញ្ហាអ្វីទេ។ អ្វីដែលយើងនិយាយនេះ គឺយើងនិយាយអំពីបរិវេណ ក-១។

[០៩:៥៧:២៥]

**ឆ៖** ក-១ ដូចខ្ញុំបានជម្រាបអំមិញហើយ គឺថាមាន-- មិនមែនជាកន្លែងធ្វើការងារមែន ហើយក៏ជាស្នាក់ការ-- អ៊ំ! ផ្ទះស្នាក់នៅរបស់អ៊ំ ប៉ុល ពត តែម្នាក់។ ក៏ប៉ុន្តែ ក្រោយមកមានការចេញចូលឃើញមានតែអ៊ំ នួន ជា ខ្ញុំឃើញទៅម្ដង។ តែប៉ុណ្ណឹងទេ។

**ស៖** សូមអរគុណចំពោះការបំភ្លឺរបស់លោក យើងសូមអរគុណ។ នៅពេលនោះ ថាតើខ្ញុំចាំយល់ត្រឹមត្រូវដែរឬទេ ដែលថា ប៉ង់ ក៏រស់នៅ ក-១ នោះដែរ? តើខ្ញុំយល់បែបនេះត្រូវដែរឬទេ?

**ឆ៖** គឺត្រឹមត្រូវ អ៊ីចឹងមែន។

[០៩:៥៨:៤៦]

**ស៖** ឥឡូវនេះយើងពិភាក្សាបន្តិចអំពី ប៉ង់។ តើលោកចាំឈ្មោះគាត់ដែរឬទេ?

**ឆ៖** ប៉ង់ ខ្ញុំចាំតែឈ្មោះគាត់ ឈ្មោះ ប៉ង់ ហ្នឹងហើយ ក្រៅពីហ្នឹងខ្ញុំអត់ឮក្រៅ ឈ្មោះក្រៅរបស់គាត់ទេ។

**ស៖** សូមអរគុណ។ លោកបានជម្រាបយើងកាលពីម្សិលមិញថា ប៉ង់ ជាអ្នកណែនាំលោកចូលបដិវត្តន៍នៅឆ្នាំ៦៦។ តើលោកដឹងទេថាតើ ប៉ង់ ហ្នឹងមកពីខេត្តណាដែរ? តើគាត់មកពីខេត្តរតនគិរី ឬក៏មកខេត្តផ្សេងទៀត?

**ឆ៖** ខ្ញុំមិនបានដឹងពីទីលំនៅរបស់គាត់ កំណើតរបស់គាត់យ៉ាងណាទេ ប៉ុន្តែខ្ញុំគ្រាន់តែជួបគ្នានៅរតនគិរីហ្នឹង ខ្ញុំដឹងថាគាត់ជាអ្នកគ្រប់គ្រងមន្ទីរនីរសារមួយហ្នឹង។ តែប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ បន្ទាប់ពីឆ្នាំ១៩៧៥ គឺបន្ទាប់ពីថ្ងៃ១៧ មេសា ៧៥ ថាតើលោកដឹងដែរឬទេថា ប៉ង់ មានតួនាទីអ្វីដែរ?

[១០:០០:៣២]

**ឆ៖** ពេលនោះខ្ញុំគ្រាន់តែដឹងថា ប៉ង់ ជាអ្នកគ្រប់គ្រងរួមក្របខ័ណ្ឌក្នុងមន្ទីរ៨៧០ គាត់ជាអ្នកទទួលខុសត្រូវរួម។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** បើតាមដែលលោកដឹង តើមន្ទីរ៨៧០ ហ្នឹងជាអ្វីដែរ?

**ឆ៖** តាមខ្ញុំដឹងខ្លះ គឺមន្ទីរ៨៧០នេះ គឺៗជាមន្ទីរក្របខ័ណ្ឌមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដែលគ្រប់គ្រងក្នុងទីនេះ ប៉ុន្តែ ប៉ង់ គាត់ជាអ្នកដាក់ស្តែងការអនុវត្តប្រចាំថ្ងៃ ការចាត់ចែងក្នុងមន្ទីរទាំងក-១ ទាំងក-៣ ទាំងក-៧ នៅលើ ប៉ង់ អ្នកចាត់ចែង។

**ស៖** សូមអរគុណ។ កាលពីម្សិលមិញលោកបានជម្រាបយើងថា តាមដែលលោកដឹង គឺ ប៉ុល ពត, នួន ជា, អៀង សារី, ខៀវ សំផន ហើយប្រហែលជា សុន សេន ផងដែរ គឺជាមេដឹកនាំជាន់ខ្ពស់។ បើតាមដែលលោកដឹង ថាតើ ប៉ង់ គឺជាមេដឹកនាំជាន់ខ្ពស់ដែរឬទេ? ឬមួយក៏គាត់មានតួនាទីផ្សេងពីនេះ?

**ឆ៖** តាមខ្ញុំយល់ពេលនោះ គឺ ប៉ង់ គឺជាជំនួយ-- ប្រៀបដូចថាជាជំនួយការ ប៉ុនន៉ុងទេ។

**ស៖** តើខ្ញុំយល់ពីលោកត្រឹមត្រូវដែរឬទេថា គាត់មិនទំនងជាមេដឹកនាំជាន់ខ្ពស់នោះទេ បានន័យថា មានឋានៈមិនជាន់ខ្ពស់ដូច ប៉ុល ពត, អៀង សារី, ខៀវ សំផន និង នួន ជា នោះទេ។ តើអ៊ីចឹងមែនដែរឬទេ?

[១០:០៣:៣៤]

**ឆ៖** គឺពិតជាអ៊ីចឹង។

**ស៖** តើលោកដឹងដែរឬទេថា ប៉ង់ រាយការណ៍ទៅអ្នកណាដែរក្នុងចំណោមមេដឹកនាំជាន់ខ្ពស់អម្បាញ់មិញនេះ? ឬក៏គាត់ទទួលការណែនាំពីនរណាដែរ?

**ឆ៖** តាមដែលខ្ញុំឃើញ គឺទទួលពី អ៊ំប៉ុល ពត ហើយ ប៉ង់ អ្នកទទួល ហើយរាយការណ៍មកវិញ ក៏រាយការណ៍មកអ៊ំ ប៉ុល ពត វិញដែរ។ ត្រង់ថារាយការណ៍ទៅថ្នាក់ណាទៀត កន្លែងណាទៀត ឬក៏អ៊ំណាទៀត ខ្ញុំអត់បានដឹងដែរ។

**ស៖** សូមអរគុណ។ តើគាត់មានធ្លាប់និយាយជាមួយលោកអំពីការងាររបស់គាត់ ជាមួយនឹងថ្នាក់ដឹកនាំជាន់ខ្ពស់ដែរឬទេ?

**ឆ៖** គាត់មិនដែលប្រាប់ ហើយខ្ញុំក៏មិនដែលបានដឹងដែរ។ ការងាររបស់គាត់ ខ្ញុំអត់បានដឹង។

**ស៖** សូមអរគុណ។ តើមានអ្វីកើតឡើងចំពោះ ប៉ង់ គាត់នៅក-១ បន្ទាប់ពីលោកចាកចេញទៀត ឬក៏យ៉ាងម៉េច?

**ឆ៖** ដែលថា ប៉ង់ បាត់ខ្លួនហ្នឹង មុនខ្ញុំចេញពីក-១។ ដល់ ប៉ង់ បាត់ខ្លួនហើយ បាន លីន ឲ្យខ្ញុំចេញដែរ ចេញទៅនៅស្វាយមាស។

**ស៖** សូមអរគុណច្រើន។ នៅពេលនោះ តើលោកដឹងថាមានអ្វីកើតឡើងចំពោះ ប៉ង់ ដែរឬទេ? ហើយហេតុអីបានជាគាត់បាត់ខ្លួន?

**ឆ៖** ពេលនោះ ខ្ញុំមិនបានដឹងពីមូលហេតុដែល ប៉ង់ បាត់ខ្លួនទេ គ្រាន់តែដឹងហេតុផលដែលថាដឹងហ្នឹង ក៏មកពីដឹងតៗតាមមិត្តភក្តិគេប្រាប់ទេថា ប៉ង់ ត្រូវចាប់ខ្លួនហើយ។ ហើយក្រោយមកបាន លីន ដើរតួម្នាក់ឯងនៅកន្លែង ប៉ង់។ ពីមុនមាន ប៉ង់ មាន លីន។ ខ្ញុំគ្រាន់តែដឹងតែប៉ុណ្ណឹងទេ។

[១០:០៧:១២]

**ស៖** សូមអរគុណ។ នៅពេលនេះ ប្រសិនបើយើងត្រឡប់ទៅនិយាយអំពីការងារដែល ប៉ង់ ធ្វើនៅមន្ទីរ៨៧០ និងមន្ទីរក-១ វិញ។ តើលោកមានធ្លាប់ចូលរួមការប្រជុំជាមួយនឹងគាត់ក្នុងពេលណាមួយដែរឬទេ?

**ឆ៖** ខ្ញុំធ្លាប់ចូលរួមជាមួយគាត់នៅពេលប្រជុំសាមញ្ញនៅក-១ តែប៉ុណ្ណឹងទេ។

**ស៖** តើមាននរណាគេផ្សេងក្រៅពីលោក និង ប៉ង់ ចូលរួមកិច្ចប្រជុំនោះដែរឬទេ?

**ឆ៖** មានសមាជិកដែលរស់នៅកន្លែងហ្នឹង ប្រហែលជាប្រាំ-ប្រាំមួយនាក់ប៉ុណ្ណឹងទេ ដែលបម្រើការកន្លែង ក-១ ហ្នឹង។

**ស៖** សូមអរគុណ។ តើមានការពិភាក្សាអ្វីដែរក្នុងការប្រជុំនោះ?

**ឆ៖** ក្នុងការប្រជុំ អត់មានពិភាក្សាការងារអីធំដុំទេ គ្រាន់តែពិភាក្សាតែការងារជុំវិញ ក-១ ហ្នឹង តាមតួនាទីរៀងៗខ្លួន គឺដូចជាខ្ញុំនៅខាងដាំបន្លែ រកបន្លែ នាំស្បៀងពីក្រៅចូលមកធ្វើម៉េចឲ្យបានទៀងទាត់ហ្មត់ចត់ ដាស់តឿន រំឭក តែប៉ុណ្ណឹង។

[១០:០៩:៥៧]

**ស៖** លោកលើកឡើងជូនយើងខ្ញុំថា មុនឆ្នាំ៧៥ លោកចូលរួមវគ្គស្វ័យទិតៀន និងវគ្គទិតៀននៅពេលយប់។ តើលោកក្រោយឆ្នាំ៧៥ មានចូលរួមវគ្គស្វ័យទិតៀន និងវគ្គទិតៀនដែរឬទេ?

**ឆ៖** ជាធម្មតា មិនថាអង្គភាពណា ឬក៏កន្លែងណាទេ ឲ្យតែពេលល្ងាចគឺត្រូវតែប្រជុំទិតៀន និងស្វ័យទិតៀនហ្នឹងហើយ។ ហើយនិងដកពិសោធន៍ការងារពីថ្ងៃ ធ្វើអី? ខុសអី? ត្រូវអី? ត្រូវតែទិតៀនគ្នាកសាងគ្នា បើយ៉ាងហោចណាស់ក៏បើមិនបានរាល់យប់ ក៏បីថ្ងៃម្តងដែរ។

**ស៖** លោកបានជម្រាបកាលពីម្សិលមិញជូនយើងខ្ញុំថា មុនឆ្នាំ៧៥ គេបង្រៀនលោកអំពីការចាំបាច់ត្រូវដកមូលធននិយម និងវណ្ណៈជិះជាន់ និងវណ្ណៈសក្តិភូមិ។ តើចំណុចទាំងអស់នេះមានគេយកទៅពិភាក្សាគ្នាក្រោយឆ្នាំ៧៥ ដែរឬទេ?

[១០:១១:៥៩]

**ឆ៖** ចំណុចទាំងនោះ គឺតាំងពីហ្នឹងមកវាតជាប់រហូត យកបញ្ហាហ្នឹងមកពិភាក្សា មកនិយាយអប់រំជាប់ហ្នឹងឯង។

**ស៖** តើលោកចាំដែរឬទេ នរណាដែរ ដែលបង្រៀនលោកអំពីចំណុចទាំងអស់នេះ?

**ឆ៖** កាលនោះ គឺមានតែ ប៉ង់ ហ្នឹងហើយអ្នកបង្រៀន។

**ស៖** តើ ប៉ង់ គាត់នោះនិយាយអំពីអ្វីដែរ អំពីខ្មាំងនោះ?

**ឆ៖** ខ្ញុំអត់ទាន់យល់ចំណុចហ្នឹង។

**ស៖** នៅពេល ប៉ង់ បង្រៀនលោកអំពីខ្មាំង តើលោក-- តើគាត់នោះនិយាយអ្វីដែលអំពីខ្មាំង? នរណាខ្លះដែរជាខ្មាំង?

[១០:១៣:៤៦]

**ឆ៖** គេ ពេលនោះគេចាត់ទុកថា ជាខ្មាំង។ ខ្មាំងហ្នឹង ដែលទីមួយ ខាងខ្មែរ គេថាខ្មែរ សេ.អ៊ី.អា របស់អាមេរិកដែលនៅបង្កប់ នៅសេសសល់។ ហើយទីពីរទៀត កា.ហ្សេ.បេ របស់សូវៀត-យួន។ បើអ្នកណាជាប់និន្នាការខាងណា ខាង កា.ហ្សេ.បេ ឬក៏ សេ.អ៊ី.អា អាហ្នឹងគឺត្រូវតែកម្ចាត់ អាន់ុងបើថាអ៊ីចឹងហើយ ដល់ពេលប្រជុំគេរំឭកៗហ្នឹង ឲ្យប្រុងប្រយ័ត្ន ដាស់តឿនកុំឲ្យ-- ឲ្យប្រុងប្រយ័ត្នរឿង កា.ហ្សេ.បេ, សេ.អ៊ី.អា ហ្នឹងជាសំខាន់។ ព្រោះពួកហ្នឹងប្រឆាំងនឹងបក្សបដិវត្តកុម្មុយនីស្តកម្ពុជា។ សូមអស់។

**ស៖** សូមអរគុណច្រើន។ តាមអ្វីដែលលោកដឹង តើមានការប្រជុំណាផ្សេងដែល ប៉ង់ បានចូលរួមដែរឬទេ?

**ឆ៖** ខ្ញុំបានដឹងតែប៉ុណ្ណឹង ហើយក្រៅពីនោះទៀត ខ្ញុំអត់បានដឹងដែរ។

**ស៖** ហើយតាមអ្វីដែលលោកនឹកឃើញ តើមានមេដឹកនាំជាន់ខ្ពស់ណាមួយ គាត់បានរៀបចំការប្រជុំនៅពេលនោះដែរឬទេ?

**ឆ៖** ខ្ញុំអត់ទាន់យល់សំណួរ អំ ក្នុងពេលនោះ មិនដឹងឆ្នាំទីប៉ុន្មាន។

**ស៖** សូមអរគុណច្រើន។ គឺនៅចន្លោះក្រោយខែមេសា ៧៥ នៅក្នុងទីក្រុងភ្នំពេញ លោកបានជម្រាបយើងខ្ញុំថា ប៉ង់ បានរៀបចំការប្រជុំ ហើយបង្រៀនលោកអំពីខ្មាំង។ នៅក្នុងអំឡុងឆ្នាំដដែលនេះ គឺក្រោយខែមេសា ៧៥ តើមានមេដឹកនាំណា-- ជាន់ខ្ពស់ណាមួយបានរៀបចំការប្រជុំដែរឬទេ?

**ឆ៖** គឺអត់មានទៀតទេ មានតែប៉ុណ្ណឹងឯង។ ខ្ញុំទទួលពី ប៉ង់ តែម្តងហ្នឹង។

**ស៖** ខ្ញុំនិយាយត្រឡប់ក្រោយបន្តិច។ លោកនិយាយថា ធ្វើការនៅ ក-១ ប្រាំមួយខែ។ ក្រោយពី ក-១ នោះ តើលោកទៅធ្វើការនៅឯណាដែរ?

[១០:១៧:៥២]

**ឆ៖** ក្រោយពី ក-១ ខ្ញុំទៅនៅព្រែកប្រា។ ព្រែកប្រានេះ គឺជាកន្លែងដាំបន្លែតិចតួច ហើយមានចម្ការមៀន ហើយនិងកន្លែងមន្ទីរកុមារតូចតាចទេ ប្រហែលជាប្អូនដប់នាក់អី ក្មេងៗ។ ប៉ុនមិនដឹងជាកូនចៅអ្នកណាអីអ្នកណា ខ្ញុំក៏មិនបានដឹង។ ហើយមានអ្នកថែទាំកុមារហ្នឹង ប្រហែលជាប្រាំ-ប្រាំមួយនាក់។ ខ្ញុំទៅនៅហ្នឹងមួយរយៈ។ ហើយក្រោយមក បានខ្ញុំទៅនៅស្វាយមាស ដែលខ្ញុំបានជម្រាបពីម្សិលមិញ។

**ស៖** នៅក្នុងអំឡុងពេលនោះ ដែលលោកធ្វើការដាំបន្លែចម្ការមៀននោះ តើលោកធ្លាប់បានទៅមន្ទីរ ក ដែលលោកហៅថា មន្ទីរក-១, ក-៣, ក-៧។ តើលោកធ្លាប់ទៅមន្ទីរទាំងអស់នោះដែរឬទេ?

**ឆ៖** ពេលនោះ ខ្ញុំធ្លាប់ទៅយូរៗម្តង យកផ្លែមៀន យកបន្លែអី វាមិនញឹកញាប់ដូចមុនទៀតទេ ខ្ញុំទៅយូរៗម្តង។

**ស៖** តើលោកអាចរៀបរាប់ជូនអង្គសវនាការ ថាតើ ក-៣ នោះ មានទ្រង់ទ្រាយយ៉ាងម៉េចដែរ? ហើយមើលទៅជាអ្វីដែរ? ទំនងមន្ទីរហ្នឹង យ៉ាងម៉េចដែរ?

[១០:២០:០៥]

**ឆ៖** បើតាមខ្ញុំសង្កេតនៅពេលនោះ គឺថា ក-៣ ជាទីប្រជុំជន ទីប្រជុំមួយរបស់ក្រុបខ័ណ្ឌមេដឹកនាំអ៊ំៗទាំងអស់ៗ ទាំងក-១, ក-៣ ទាំងអ៊ំ ប៉ុល, ទាំងអ៊ំ ហែម, ទាំងអ៊ំ នួន ជា, ទាំងអ៊ំ ខៀវ សំផន, ទាំងអ៊ំ សុន សេន។ ខ្ញុំ បានខ្ញុំថាអ៊ីចឹង ខ្ញុំបានឃើញនៅទីនោះមានឈ្មោះប៉ុណ្ណឹងនាក់ ចេញចូលកន្លែងហ្នឹង ហើយមាន ជួនកាលវាបើកវគ្គ។ បើកវគ្គហ្នឹង មិនមែនវគ្គធំៗ មហាជន សម្រាប់មហាជនអីទេ គឺក្រុបខ័ណ្ឌគាត់ប៉ុន្មាននាក់ហ្នឹង។ ប៉ុន្តែវគ្គអីយ៉ាងណា ខ្ញុំមិនបានដឹងទេ ប៉ុន្តែតែថា ដឹងថាបើកវគ្គធ្វើការងារសម្រាប់ក្រុបខ័ណ្ឌគាត់ប៉ុន្មាននាក់ហ្នឹង។ ហើយខ្ញុំគ្រាន់ជាអ្នកបម្រើខាងបាយទឹក ជួយរកបន្លែ រកបង្ការបម្រើនៅក្នុងវគ្គនោះ។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

[១០:២១:៤៣]

**ស៖** នៅក្នុងក្រុមមនុស្សដែលលោករៀបរាប់អម្បាញ់មិញ តើ អៀង សារី ស្ថិតនៅក្នុងក្រុមនេះដែរឬទេ ឬក៏មិនស្ថិតនៅក្នុងក្រុមនេះទេ?

**ឆ៖** បាទ ស្ថិតនៅជាមួយគ្នាទាំងអស់ ប្រមូលផ្តុំនៅ ក-៣ ហ្នឹង។ ប៉ុន្តែចំពោះអ៊ំ ខៀវៗ ហៅ អ៊ំ សុន សេន គាត់គ្រាន់តែចល័តមកម្តងម្កាល ពេលមកធ្វើការជួបជុំគ្នាទេ មិនដឹងទីតាំងគាត់ពិតប្រាកដនៅកន្លែងណាទេ។

**ស៖** សូមអរគុណ។ តើលោកដឹងគោលបំណងដែលថាវគ្គ បើកវគ្គនោះ គេមានគោលបំណងអ្វីដែរ?

**ឆ៖** ពេលនោះ ខ្ញុំមិនបានដឹងទាំងអស់ ព្រោះនេះជាការសម្ងាត់របស់មេដឹកនាំ។ មិនអាចខ្ញុំយល់ដឹងបានទេ។ ពីបំណងយ៉ាងណា ហើយក៏ទិសដៅម៉េច ក៏ខ្ញុំមិនបានយល់។

**ស៖** តើលោកធ្លាប់ឮគណៈអចិន្ត្រៃយ៍ដែរឬទេ?

**ឆ៖** ខ្ញុំអត់ដែលឮ ហើយម្យ៉ាងក៏ខ្ញុំ ខ្ញុំមិនបានយល់ជ្រៅក្នុងបញ្ហាហ្នឹង ព្រោះខ្ញុំជាមហាជនធម្មតា មិនមែនជាអ្នកដឹកនាំ មិនអាចយល់ច្រើន។

[១០:២៤:០៣]

**ស៖** តាមអ្វីដែលលោកដឹង តើ ខៀវ សំផន ធ្លាប់ជួបប្រជុំជាមួយនឹងកម្មាភិបាលមកពីមន្ទីរ កដែរឬទេ?

**ឆ៖** ខ្ញុំអត់ដែរឃើញទេ។ ឃើញគាត់ គ្រាន់តែ ខ្ញុំដឹងថាគាត់នៅកន្លែង ក-៣ ហ្នឹង។ ប៉ុន្តែគាត់ធ្វើប្រជុំការងារអី ខ្ញុំអត់បានដឹងដែរ?

[១០:២៥:០២]

**ស៖** លោក ពាន ឃាន ខ្ញុំបានសួរលោកអំពីហេតុការណ៍ដែលបានកើតឡើងយូរឆ្នាំមកហើយ វាពិបាកក្នុងការឲ្យលោករម្លឹកឡើងវិញផងដែរ។ ដូច្នេះត្រង់ចំណុចនេះ គឺខ្ញុំនឹងសួរលោកអំពីការស្តាប់ចម្លើយមុនៗដែលលោកគិតថាលោកបានឆ្លើយប្រាប់គេ។ តើលោកនឹកឃើញដែរឬទេថា លោកធ្លាប់បានជួបជាមួយនឹងក្រុមអ្នកស្រាវស្រាវក្នុងឆ្នាំ២០០៥ ហើយនៅពេលនោះ លោកបានរៀបរាប់អំពីហេតុការណ៍ទាំងអស់នេះជូនគេ។ តើលោកនឹកឃើញដែរឬទេ?

**ឆ៖** ខ្ញុំចាំអត់បាន យូរពេកហើយ ភ្លេចអស់។

**ស៖** ក្រៅពីការសួរ ការសម្ភាសដោយអ្នកស៊ើបអង្កេតដែលជាបុគ្គលិករបស់តុលាការនេះ តើលោកធ្លាប់មានអ្នកផ្សេងសម្ភាសលោក សួរអំពីហេតុការណ៍កម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** គឺអត់មានណាដែលសួរទេ។ ខ្ញុំសម្ភាសតែពីរដងគត់។ ក្រៅពីហ្នឹងអត់មាន។

[១០:២៦:៥៣]

**ស៖** លោកនិយាយថាសួរតែពីរដង ម្តងគឺសួរសម្ភាសដោយអ្នកស៊ើបអង្កេតពីតុលាការនេះ តើអ៊ីចឹងដែរឬទេ?

**ឆ៖** *(មិនឮសំឡេង)*

**ស៖** បាទ លោកអត់ទាន់បានឆ្លើយ ហើយខ្ញុំស្តាប់អត់ឮដែរ តាមការបកប្រែជាភាសាអង់គ្លេស។ ខ្ញុំនឹងសួរសំណួរឡើងវិញ។ កិច្ចសម្ភាសន៍ពីរដងនេះ មានម្តងសម្ភាសជាមួយនឹងអ្នកស៊ើបអង្កេតពីតុលាការនេះ។ អ៊ីចឹងដែរឬទេ?

**ឆ៖** សម្ភាសខាងតុលាការហ្នឹងគេ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទសូមអរគុណ។ ខ្ញុំយល់ថា អ្វីដែលលោកព្រះរាជអាជ្ញាបានសួរអម្បាញ់មិញ ជាសំណួរនាំមុខ ព្រោះសាក្សីបានឆ្លើយថា សម្ភាសបានពីរដង ប៉ុន្តែគាត់មិនបានបញ្ជាក់ថាម្តងមកពីខាងណាទេ។ លោកគួរតែសួរថាតើពីរដងហ្នឹង ពីកន្លែងណាខ្លះ? អ្នកណាខ្លះអ្នកសម្ភាស? មិនមែនបញ្ជាក់ថា ម្តងមកពីតុលាការនេះទេបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ សេចក្តីជំទាស់របស់មេធាវីមានប្រសិទ្ធភាព។ សំណួរអម្បាញ់មិញច្រំដែល អំសំណួរនាំមុខ។ ដូច្នេះសូមតំណាងសហព្រះរាជអាជ្ញាកែសម្រួលនូវការតាំងសំណួរ ចៀសវាងនូវសំណួរនាំមុខ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់បង្ហាញឯកសារមួយជូនសាក្សីដែលអង្គជំនុំជម្រះបានទទួលយកកាលពីម្សិលមិញ គឺឯកសារ E187.1 វាជាឯកសារសង្ខេប ដែលយើងបានពិភាក្សាគ្នាកាលពីម្សិល

មិញ។ គឺខ្ញុំមិនដឹងថា តើការសម្ភាសនោះវាមានលក្ខណៈច្បាស់ប៉ុនណា ហើយវាយ៉ាងម៉េចនោះទេ។ ដូច្នេះហើយគឺខ្ញុំសូមបង្ហាញឯកសារនេះជូនដល់សាក្សី។

[១០:២៩:២៣]

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះអនុញ្ញាត ប៉ុន្តែឥឡូវនេះពេលវេលាដល់សមល្មមនឹងសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយចំណែកឯការដាក់ឯកសារស្នើសុំអម្បាញ់មិញនេះ អង្គជំនុំជម្រះនឹងសម្រេច និងឲ្យបន្តធ្វើក្រោយពេលដែលចូលមក ត្រឡប់មកបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្រួលកន្លែងសម្រាកនៅបន្ទប់សម្រាកសម្រាប់សាក្សី ដល់សាក្សីរូបនេះ ហើយនិងមេធាវីប្រឹក្សារបស់គាត់ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ដោយសារបញ្ហាសុខភាព ជាពិសេសបញ្ហាឈឺចង្កេះ ឆ្អឹងខ្នង និងជើង លោក អៀង សារី ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការសម្រាប់រយៈពេលសេសសល់ទាំងអស់ថ្ងៃនេះ។ ប៉ុន្តែ សូមចូលរួមដោយប្រយោលពីបន្ទប់រង់ចាំខាងក្រោម។ អាស្រ័យហេតុនេះសូមលោកប្រធានមេត្តាសម្រេច។ សូមអរគុណ។

[១០:៣០:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គុយចុះ!

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ស្នើសុំលះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចដំណើរការសវនាការផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយសុំបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ ដោយមូលហេតុបញ្ហាសុខភាពមិនអាចអង្គុយតាមដាននៅក្នុងកិច្ចដំណើរសវនាការដោយផ្ទាល់បានយូរ។

ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែល

បានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ សម្រាប់ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលនៃកិច្ចដំណើរការសម្រាប់ថ្ងៃនេះ ចាប់ពីពេលនេះតទៅរហូតដល់ចប់នៅវេលារសៀល។

[១០:៣១:៣៧]

ហើយអង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តី អៀង សារី ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ដោយជនជាប់ចោទ អៀង សារី។

ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍តភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ អៀង សារី ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះ ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់ជនជាប់ចោទអាចចូលរួម និងបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោមឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣២ នាទី ដល់ម៉ោង១១:១៣ នាទី)*

[១១:១៣:៥៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគី និងសាធារណជនបានជ្រាបថា ដោយសាក្សី ពាន ឃាន គាត់មានបញ្ហាសុខភាពធ្ងន់ធ្ងរមិនអាចបន្តផ្តល់សក្ខីកម្មបាន។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចផ្អាកនៅក្នុងកិច្ចដំណើរការសវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះ នៅពេលនេះ ហើយកិច្ចដំណើរការសវនាការលើកទៅបន្តធ្វើនៅថ្ងៃអង្គារ អឺ! បន្តធ្វើនៅថ្ងៃព្រហស្បតិ៍ និងថ្ងៃសុក្រទី១៧ និងទី១៨ ខែឧសភា ឆ្នាំ២០១២។ អឺចឹងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ច

ដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១១:១៥ នាទី)*